# មន្ត្រីរដ្ឋាភិបាលមូលដ្ឋានជាង១០០នាក់មកពី៦ប្រទេសនិងសហភាពអឺរ៉ុបជួបពិភាក្សាស្ដីពីអភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍នៅថៃ

**ភ្នំពេញ ៖** បណ្ដាញគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ (DELGOSEA) កំពុងតែជំរុញឱ្យមានការបង្កើតវេទិកាពិភាក្សាមួយមានលក្ខណៈអចិន្ត្រៃយ៍ស្ដីពីវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋានរវាងប្រទេសជាសមាជិកអាស៊ាន និងសម្រាប់ការពង្រីកកិច្ចសហការជាមួយនឹងរដ្ឋអំណាចមូលដ្ឋាន និងសង្គមស៊ីវិលតាមអភិក្រមសហអ្នកពាក់ព័ន្ធ។ អាស៊ានបានទទួលស្គាល់ពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការស្ដីពីអភិបាលកិច្ចមូលដ្ឋានក្នុងគោលបំណងធានាឱ្យមានស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងប្រទេសអាស៊ីភាគអាគ្នេយ៍បានប្រសើរឡើង និងការគាំទ្រដល់អភិក្រមរួមគ្នារវាងប្រទេសជាសមាជិកក៏កំពុងតែរីកចម្រើនផងដែរ។

សន្និសីទនេះនឹងប្រារព្ធធ្វើឡើងនៅទីក្រុងបាងកក ប្រទេសថៃពីថ្ងៃទី៧និងទី៨ ខែសីហា ឆ្នាំ២០១២ ដែលបង្ហាញពីសញ្ញានៃការបញ្ចប់គម្រោងដែលមានការផ្ដល់សហហិរញ្ញប្បទានពីសហភាពអឺរ៉ុប។ សន្និសីទនេះត្រូវបានធ្វើជាម្ចាស់ផ្ទះដោយសម្ព័ន្ធភាពទីក្រុងរបស់ថៃ(MLT) និង Konrad-Adenauer-Stiftung (KAS) តំណាងឱ្យគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ (DELGOSEA) និងមានការចូលរួមជាង១៥០នាក់ ជាតំណាងដៃគូគម្រោងសមាគមរដ្ឋបាលមូលដ្ឋានបណ្ដាទីក្រុងចូលរួមសាកល្បងអនុវត្តបទពិសោធន៍ពិនិត្យមើលស្ថាប័ន និងអង្គការនានាដែលអាចនឹងមានបំណងផ្ដល់ប្រព័ន្ធគាំទ្រដល់ទីក្រុងជាសមាគមអាជ្ញាធរមូលដ្ឋាន សមាគមថ្នាក់តំបន់ដូចជា United Cities and Local Governments (UCLG)សហភាពអឺរ៉ុបគណៈកម្មាធិការនានាក្នុងតំបន់។ល។ សន្និសីទក៏នឹងធ្វើការពិភាក្សាផងដែរលើតួនាទីនៃស្ថាប័នទាំងនោះនិងថាតើស្ថាប័ននានាទាំងនោះនឹងអាចចូលរួមដល់ការពង្រឹងអភិបាលកិច្ចមូលដ្ឋានល្អនៅតំបន់អាស៊ីភាគអាគ្នេយ៍យ៉ាងដូចម្ដេច។

តាមប្រសាសន៍របស់អ្នកស្រី ស៊ូហ្សាន ស្ទេហ្វេន(Susanne Stephan) នាយកគម្រោង DELGOSEA "សន្និសីទចុង ក្រោយនេះ គឺមិនមែនជាដំណាក់កាលបញ្ចប់នោះទេ តែគ្រាន់តែជាការបញ្ចប់ជំពូកមួយ និងចាប់ផ្ដើមជំពូកថ្មីមួយតែប៉ុណ្ណោះ។ សន្និសីទនេះជាឱកាសដើម្បីពិនិត្យមើលនូវអ្វីដែលសម្រេចបាន និងក្នុងពេលតែមួយយើងអាចពិភាក្សាលើផែនទីបង្ហាញផ្លូវសម្រាប់ការរៀនសូត្របន្ថែមទៀត និងផ្លាស់ប្ដូររវាងរដ្ឋបាលមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ ក៏ដូចជាពង្រឹងនូវតួនាទីរបស់ខ្លួនក្នុងកម្រិតថ្នាក់តំបន់នាពេលអនាគត"។

នាយកគម្រោងបន្ថែមថា "ពីរឆ្នាំកន្លះនៃជោគជ័យបានកន្លងផុតទៅ ហើយបណ្ដាឆ្នាំជោគជ័យប្រសើរជាងនេះស្ថិតនៅពីមុខយើង"។

ទាក់ទងនឹងគម្រោងសេចក្ដីប្រកាសព័ត៌មានបានឱ្យដឹងថា ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (DELGOSEA) បង្កើតបណ្ដាញ៣២ទីក្រុងនិងខេត្តនានា ដើម្បីអនុវត្តតាមការអនុវត្តន៍ល្អនៃអភិបាលកិច្ចអន្តរតំបន់ទៅដល់ប្រទេសជាដៃគូនានា ដូចជា កម្ពុជា ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ និងវៀតណាម។

បណ្ដាញនេះត្រូវបានគាំទ្រដោយសមាគមរដ្ឋាភិបាលមូលដ្ឋានចំនួន១១ រដ្ឋអំណាចមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានអប់រំ និងបណ្ដាញសារព័ត៌មាននានា និងគាំទ្រតួនាទីក្នុងការផ្ដល់ឱ្យ និងជួយដល់ការផ្ទេរ និងនិរន្តរភាពនៃការអនុវត្តន៍ តាមការអនុវត្តន៍ល្អនៃអភិបាលកិច្ចមូលដ្ឋាន និងត្រូវបានគ្រប់គ្រងដោយអង្គការខុនរ៉ាដ Konrad-Adenauer-Stiftung (KAS) សហការឧបត្ថម្ភដោយសហភាពអឺរ៉ុបនៃប្រទេសអាល្លឺម៉ង់តាមរយៈក្រសួងសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសអាល្លឺម៉ង់៕

**សុផល**

# មន្ត្រីអប់រំបរិស្ថានៈ អាកាសធាតុប្រែប្រួលក្ដៅខ្លាំង

**ភ្នំពេញ៖** ក្រុមមន្ត្រីអប់រំបាននិយាយថា បរិយាកាសប្រឡងឆ្នាំនេះបកើតទៅលជាងឆាំមុន និងមាន

